**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ១៦៧ MIH / ២០១៨

# សេចក្តីជូនដំណឹង
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់សញ្ញាផលិតផលកម្ពុជាមានគុណភាព

ក្នុងគោលបំណងជំរុញការអភិវឌ្ឍរោងចក្រ សហគ្រាស និងសិប្បកម្ម ឱ្យមានការលូតលាស់ រីកចម្រើន តាមរយៈការលើកស្ទួយផលិតផលឧស្សាហកម្ម សហគ្រាស និងសិប្បកម្មកម្ពុជា ឱ្យមានភាពប្រកួតប្រជែង និងផ្តល់ជំនឿទុកចិត្តចំពោះអ្នកប្រើប្រាស់លើផលិតផលឧស្សាហកម្ម និងសិប្បកម្មក្នុងស្រុក ឱ្យធានាបាននូវសុខុមាលភាពសាធារណៈ សុវត្ថិភាព បរិស្ថាន និងសង្គម ក្រសួងឧស្សាហកម្ម និងសិប្បកម្ម មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ម្ចាស់រោងចក្រ សហគ្រាស និងសិប្បកម្ម ស្ថាប័ន អង្គភាពពាក់ព័ន្ធ និងវិស័យឯកជន ឱ្យបានជ្រាបថា ៖ ក្រសួងនឹងដាក់ចេញឱ្យអនុវត្តនូវប្រកាស ស្តីពី **ការកំណត់សញ្ញាផលិតផលកម្ពុជាមានគុណភាព** លេខ ១០៧ MIH/2017 ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧ តាមរយៈសេចក្តីណែនាំលេខ ៣០៩៣ MIH/2017 ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៧។

ម្ចាស់រោងចក្រ សហគ្រាស និងសិប្បកម្ម ទាំងឡាយណាដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ អាចបំពេញបែបបទដាក់ពាក្យស្នើសុំ **សញ្ញាផលិតផលកម្ពុជាមានគុណភាព** នៅច្រកចេញចូលតែមួយនៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម រៀងរាល់ម៉ោងធ្វើការ។

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម នឹងធ្វើការត្រួតពិនិត្យលក្ខខណ្ឌចាំបាច់មួយចំនួនពីម្ចាស់រោងចក្រ សហគ្រាស និងសិប្បកម្ម ជាអ្នកស្នើសុំ មុននឹងអនុម័តចេញវិញ្ញាបនបត្របញ្ជាក់ **សញ្ញាផលិតផលកម្ពុជាមានគុណភាព** ជូន។

អាស័យដ្ឋានទំនាក់ទំនង ៖ ច្រកចេញចូលតែមួយ នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម ជាន់ផ្ទាល់ដី លេខ៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទលេខ៖ ០២៣ ២១០ ៣៥៧ និងគេហទំព័រ ៖ www.mih.gov.kh ។

អាស្រ័យហេតុនេះ សូម លោក លោកស្រី ជាម្ចាស់រោងចក្រ សហគ្រាស និងសិប្បកម្មទាំងអស់ មេត្តាជ្រាប និងចូលរួមអនុវត្តតាមការជូនដំណឹងនេះ។

ថ្ងៃចន្ទ ១១ កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ២០១៨
**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម ប្រសិទ្ធ**